**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>ក្រសួងឧស្សាហកម្ម និងសិប្បកម្ម</u>

ខេត្តកែប-ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៦៖ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ដឹកនាំប្រតិភូក្រុមការងារក្រសួង និងតំណាងអាជ្ញាធរខេត្តចុះពិនិត្យសមិទ្ធិផលនានាក្នុងខេត្តកែប៖ ស្រះទឹកធំៗសរុប ចំនួន០៧ កន្លែង ក្នុងនោះស្រះទឹកចំនួន០៤ ស្ថិតនៅក្នុងសង្កាត់អង្កោល ក្រុងកែប ខេត្តកែប ស្រះទឹកចំនួន ០២ ស្ថិតនៅភូមិទួលសាង៉ាំ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ និងស្រះទឹកចំនួន ០១ ស្ថិតនៅឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្ត កែប ដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** តាមរយៈ **ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកែប** ហើយត្រូវអនុវត្តដោយក្រុមការងារចុះតាមភូមិនីមួយៗ ត្រូវបានឯកឧត្តម **ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** ដឹកនាំប្រតិភូក្រុមការងារក្រសួង និងតំណាងអាជ្ញាធរខេត្តចុះពិនិត្យនិងណែនាំជាក់ស្តែង នៅព្រឹកថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៦ ដោយទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅ និងដឹងគុណយ៉ាងជ្រាលជ្រៅពីសំណាក់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន។



*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

មានប្រសាសន៍សំណេះសំណាល នាឱកាសនោះ ឯកឧត្តមទេស រដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថា៖ អំណោយដ៏ថ្លៃថ្លារបស់សម្តេចតេជោនេះ គឺដើម្បីដោះស្រាយ និងទប់ទល់នូវភាពរាំងស្ងួត ដែល នឹងអាចអូសបន្លាយជាយថាហេតុ ដោយបាតុភូតធម្មជាតិ នៅក្នុងរដូវប្រាំងក្តៅហែង ដូចដែលធ្លាប់កើតមានកាលពីខែប្រាំងកន្លងទៅថ្មីៗនេះ ដែលពេលនោះសម្តេចបានចេញ យុទ្ធនាការចែកទឹកទូទាំងប្រទេស និងបានដាក់ចេញនូវផែនការស្តារស្រះចាស់ ជីកស្រះថ្មី រីស្តារអណ្តូងចាស់ ជីកអណ្តូងថ្មី ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានណែនាំប្រជាពលរដ្ឋ និងអាជ្ញាធរឲ្យខិតខំថែរក្សាសមិទ្ធិផលរួមនេះ ដោយត្រូវ រក្សាអនាម័យ និងបរិស្ថានល្អជុំវិញស្រះទឹក និងមិនត្រូវយកទឹកក្នុងស្រះធ្វើអាជីវកម្ម ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ។











*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ស្ថិតក្នុងឱកាសនោះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី និងគណៈប្រតិភូ ក៏បានចុះពិនិត្យ ស្វែងយល់ពីដំណើរការសិក្សាជំនាញ កំព្យូទ័រ និងភាសាអង់គ្លេស របស់យុវជន និងកុមារា កុមារី ដែលក្រុមការងារបានរៀបចំអនុវត្ត តាមប្រសាសន៍ណែនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ដើម្បីលើកកំពស់ធុនធានមនុស្សនៅមូលដ្ឋានផ្ទាល់ តាមរយៈការជួលគ្រូបង្រៀនមកបង្រៀនកូនចៅប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅទីស្នាក់ការគណបក្សភូមិ និងឃុំ ។ ក្នុងនោះឯកឧត្តមទេសរដ្ឋមន្ត្រី ជាអ្នកឧបត្ថម្ភកំព្យូទ័រមួយកំប្លេរ និងថ្លៃឈ្នួលគ្រូបង្រៀន។ ជាក់ស្តែង ក្នុងឱកាស សំណេះសំណាលជាមួយកុមារា កុមារី ជាកូនចៅប្រជាពលរដ្ឋ ដែល មកសិក្សាភាសាអង់គ្លេស ក្នុងទីស្នាក់ការគណបក្សភូមិថ្មី សង្កាត់ ព្រៃធំ ក្រុងកែប ខេត្ត កែប ប្រមាណ ៨០ នាក់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានសម្រេច បន្ថែមម៉ោងសិក្សាចំនួន ០១ ម៉ោងទៀត សម្រាប់មនុស្សធំ និងមនុស្សចាស់ ពីព្រោះមានប្រយោជន៍សម្រាប់ការងារទំនាក់ទំនង និងលក់ដូរ អាជីវកម្ម ពីព្រោះខេត្តកែបជាខេត្តទេសចរណ៍ដ៏មានសក្តានុពល ។ ដោយឡែកសិស្សក្មេងៗ ដែលទទួលចំណាត់ថ្នាក់ចាប់ពី លេខ១ ដល់លេខ២០ នឹងទទួលការឧបត្ថម្ភកង់ម្នាក់០១ គ្រឿង ។



*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**









*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**Ministry of Industry & Handicraft**

Kep 31st July, 2016: His Excellency CHAM PRASIDH, Senior Minister of Ministry of Industry & Handicraft and delegates pay a visit to Kep province to inaugurate 07 newly dug ponds, donated **by Samdech Akeakmohasenabadei Techo Hun Sen, Prime Minister of Cambodia.** These new infrastructures will not only assist the locals but also help them prepare for the severe drought or other unpredictable changes of climate. His Excellency, who is also a national committee chief of working group for Kep province for **Cambodian People Party** notes that these pond shall serve everyone, belong to the public and shall not be abused for personal advantages. His Excellency has also called for the locals to jointly protect the ponds environment for sustainable use during the opening event which has been warmly welcomed by the locals and authority.

After the visit, His Excellency Senior Minister CHAM Prasidh and delegates of Ministry of Industry & Handicraft have come over to witness the progress of English language and computer training for young kids within the building of village-commune party office, a program initiated and sponsored by His Excellency including teachers' fee and computer machines to boost skill for youngsters. The training is free of charge at Cambodian People Party office located at Thmey village, Sangkat Prey Thom, Kep province. During the discussion with 80 students in the office, His Excellency has pledged to add another hour for adult and elderly people to enhance communication skill for the locals to do businesses with tourists. A set of computer has been donated and as an act of encouragement to young students, those who earned first to twentieth grade received a new bicycle from His Excellency. (www.mih.gov.kh)